ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ១១៤៨/២០-១២-២០១១

សាលដីកា
លេខ៧៧ "ក្រ២ង"
ចុះថ្ងៃទី១១-១០-២០១៣

# គាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទីដប់មួយ ខែតុលា ឆ្នាំពីរពាន់ដប់បី ដូចខាងក្រោម:

## ក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ក្រុមប្រឹក្សា

លោក [redacted] ក្រុមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ១១៤៨ ចុះថ្ងៃទី២០-១២-២០១១ រវាង:

-ជនជាប់ចោទឈ្មោះ [redacted] ចេវា ភេទប្រុស អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរៈពាណិជ្ជករ ទីកន្លែងកំណើតនៅ [redacted] ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។

-ចាប់ខ្លួនថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ។

-មេធាវីការពារ លោក [redacted] ចំរើន

**ត្រូវចោទពីបទ:** រំលោភលើសេចក្តីទុកចិត្ត

ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦-៣-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៥៦ឆ្នាំ មានទីលំនៅផ្ទះលេខ [redacted] ។

# ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី១៦.០៨.២០០៨ ឈ្មោះ [redacted] រចនា បានឲ្យឈ្មោះ [redacted] មឿន បូមខ្សាច់ដាក់បំពេញទីលាននៅការដ្ឋានរបស់ខ្លួន ដែលមានទីតាំងនៅភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ក្រោយពីមានការឯកភាពគ្នាហើយឈ្មោះ [redacted] មឿន បានចាប់ផ្ដើមដំណើរការបូមខ្សាច់ចាក់ការដ្ឋាន ដោយការបូមខ្សាច់នោះ គិតមកដល់ថ្ងៃ០១-០២-២០០៩ សរុបជាទឹកប្រាក់ចំនួន១០០.៧០៣ដុល្លាអាមេរិក (ដប់ម៉ឺនប្រាំពីររយបីដុល្លាអាមេរិក) ។ លុះដល់ពេលឈ្មោះ [redacted] មឿន ទៅសួរនាំ ទារយកប្រាក់ឈ្មោះ [redacted] រចនា បានសន្យាថា ថ្ងៃនេះថ្ងៃនោះ និងសុំឲ្យឈ្មោះ [redacted] មឿន បូមខ្សាច់ចាក់បន្តទៀត ។ ដោយមានការជឿទុកចិត្ត ដើមបណ្ដឹងក៏បូមខ្សាច់ចាក់បន្តទៀត រហូតដល់អស់ទឹកប្រាក់សរុបចំនួន ១៣៨.០១៧ ដុល្លាអាមេរិក(ដប់បីម៉ឺនប្រាំបីពាន់ដប់ប្រាំពីរដុល្លាអាមេរិក)ដែលឈ្មោះ [redacted] រចនា មិនព្រមប្រគល់ឲ្យឈ្មោះ [redacted] មឿន ពេលឈ្មោះ [redacted] មឿន ទៅទារប្រាក់ឈ្មោះ [redacted] រចនា បានព្យាយាមគេចវេសពុំព្រមលើកទូរស័ព្ទទៀត ។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា: ចំពោះថ្លៃឈ្នួលបូមខ្សាច់របស់ឈ្មោះ [redacted] មឿន ដែលបានបូមខ្សាច់ដាក់ឲ្យការដ្ឋានរបស់ខ្លួននោះ ខ្លួនទទួលស្គាល់ចំនួន១០០៧០៣ ដុល្លាអាមេរិក(ដប់ម៉ឺនប្រាំពីររយបីដុល្លាអាមេរិក) ដូចមានលិខិតទូទាត់ប្រាក់រវាងខ្លួននិងឈ្មោះ [redacted] មឿន ចុះថ្ងៃទី០១-០២-២០០៩ស្រាប់ ។ ចំពោះថ្លៃឈ្នួលបូមខ្សាច់របស់ឈ្មោះ [redacted] មឿន ដែលមានលិខិតទូទាត់ប្រាក់ចំនួន ០៤សន្លឹក ចុះថ្ងៃ២២-០២-២០០៩ ចុះថ្ងៃ១៥-០២-២០០៩ ចុះថ្ងៃ០១-០៣-២០០៩ និងចុះថ្ងៃ០១-០៣-២០០៩ នោះខ្លួនពុំទាន់ឯកភាពទេ ដោយហេតុថា ខ្លួនពុំទាន់បានចុះទៅវាស់បរិមាណទូកដែលបូមខ្សាច់ដាក់នោះ តែចំពោះចំនួនទូកខ្លួនទទួលស្គាល់ដែលមានឈ្មោះ [redacted] វុទ្ធី បានចុះហត្ថលេខាទទួលដឹងឮ ព្រោះឈ្មោះនេះ ជាមេការក្នុងការងារបូមខ្សាច់ដាក់ការដ្ឋានរបស់ខ្លួន ចំពោះប្រាក់ដែលខ្លួននូវជំពាក់ថ្លៃឈ្នួលបូមខ្សាច់របស់ឈ្មោះ [redacted] មឿន នោះ គឺកន្លងមកខ្លួនធ្លាប់ទូទាត់លើកទី១មានទឹកប្រាក់ចំនួន៣៨៥០០ ដុល្លាអាមេរិក និងលើកទី២ខ្លួនបានទូទាត់ទៅឲ្យឈ្មោះ [redacted] យាង ជំនួស [redacted] មឿន ចំនួន៤៣០០០ដុល្លាអាមេរិក ។ ចំពោះប្រាក់ចំនួន ៣៨៥០០ដុល្លាអាមេរិក គឺឈ្មោះ [redacted] លាប ជាមេការរបស់ខ្លួនបានប្រគល់ចំនួនបីដង ឲ្យទៅកូន [redacted] មឿន ឈ្មោះ ខំ ជាអ្នកទទួល ចំពោះប្រាក់ដែលនៅសល់គឺខ្លួនសូមឈ្មោះ [redacted] មឿន បូមខ្សាច់ចាក់បំពេញការដ្ឋានខ្លួនគ្រប់មួយម៉ឺនម៉ែត្រគូបទៀតទើបខ្លួនប្រគល់ប្រាក់ឲ្យទៅគាត់ ។

-បានឃើញចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មឿន បានឆ្លើយថា:នៅថ្ងៃទី០៦-៨-២០០៨ ឈ្មោះ [redacted] រចនា បានមកជួលខ្លួនឲ្យបូមខ្សាច់ដាក់ការដ្ឋានភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ហើយក៏ព្រមព្រៀងតម្លៃគ្នា ក្រោយពីព្រមព្រៀងគ្នាហើយ ខ្លួនក៏ចាប់ផ្ដើមដឹកខ្សាច់ដាក់ការដ្ឋាន ហើយឈ្មោះ [redacted] រចនា ឆ្លើយថាថ្ងៃនេះថ្ងៃនោះ ដោះសាររហូត ហើយគាត់បានឲ្យខ្លួនបូមខ្សាច់ដាក់ការដ្ឋានបន្ត រហូតមកដល់ពេលនេះឈ្មោះ [redacted] រចនា នៅខ្វះលុយខ្លួនចំនួន១៣៨.០១៧ដុល្លាអាមេរិក (ដប់បីម៉ឺនប្រាំបីពាន់ដប់ប្រាំពីរដុល្លាអាមេរិក) ដែលពុំបានទូទាត់ប្រាក់ឲ្យខ្លួននៅឡើយ។ ខ្លួនបានទាក់ទងទៅឈ្មោះ [redacted] រចនា ដើម្បីទូទាត់លុយ តែគាត់បានគេចវេសរហូត។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ធានី បានឆ្លើយថា: កាលពីឆ្នាំ២០០៨ ឈ្មោះ [redacted] រចនា

បានមកជួបឈ្មោះ [redacted] មឿន ត្រូវឪពុករបស់ខ្លួន ហើយបានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាត្រឹមត្រូវដោយឈ្មោះ [redacted] រចនា បានជួលឪពុកខ្លួនដឹកខ្សាច់ និងបូមខ្សាច់ដាក់ការដ្ឋានរបស់ [redacted] រចនា ក្រោយពីព្រមព្រៀងគ្នាហើយ ឪពុកខ្លួនបានដំណើរការបូមខ្សាច់ដាក់ខ្សាច់ដាក់ការដ្ឋានរបស់ឈ្មោះ [redacted] រចនា ហើយឈ្មោះ [redacted] រចនា មិនបានទូទាត់ឲ្យលុយមកឪពុកខ្លួនគ្រប់ទេ ដោយនៅខ្វះចំនួន១៣៨.០១៧ ដុល្លាអាមេរិក ( ដប់បីម៉ឺនប្រាំបីពាន់ដប់ប្រាំពីរដុល្លារអាមេរិក) តាំងពីពេលដឹកខ្សាច់បំពេញការដ្ឋាន ហើយឈ្មោះ [redacted] រចនា បានគេចវេសមិនព្រមទូទាត់លុយថ្លៃដឹកខ្សាច់នោះទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុថារ៉ា បានឆ្លើយបំភ្លឺថា:ឈ្មោះ [redacted] មឿន បានទទួលម៉ៅការបូមខ្សាច់ពីឈ្មោះ [redacted] រចនា ហើយឈ្មោះ [redacted] មឿន បានជួលបន្តឲ្យខ្លួនជាអ្នកបូមខ្សាច់ ដាក់ការដ្ឋានរបស់ឈ្មោះ [redacted] រចនា នោះ ។ ចាប់តាំងពីការបូមខ្សាច់រហូតមកឈ្មោះ [redacted] រចនា ពុំទាន់បានទូទាត់ប្រាក់ឲ្យឈ្មោះ [redacted] មឿន ទេ ។ តាមខ្លួនដឹងឈ្មោះ [redacted] រចនា បានព្យាយាមគេចវេសពុំព្រមទូទាត់ប្រាក់ថ្លៃឈ្នួលបូមខ្សាច់ឲ្យទៅ ឈ្មោះ [redacted] មឿន ឡើយ ព្រោះពេលខ្លះឈ្មោះ [redacted] មឿន បានទូរស័ព្ទទៅឈ្មោះ [redacted] រចនា ចំពោះមុខខ្លួន តែគាត់ពុំព្រមទទួលទូរសព្ទ័ទេ។

-បានឃើញចម្លើយរបស់សាក្សីឈ្មោះ មាន ចាន់ណា បានឆ្លើយបំភ្លឺថា: ខ្លួនបានដឹងថាឈ្មោះ [redacted] មឿន បានទទួលម៉ៅការបូមខ្សាច់ឲ្យឈ្មោះ [redacted] រចនា ដែលមានទីតាំងភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពីដំបូងឈ្មោះ [redacted] រចនា បានទូទាត់ប្រាក់ឲ្យឈ្មោះ [redacted] មឿន តែក្រោយមកឈ្មោះ [redacted] រចនា មិនបានទូទាត់ប្រាក់ឲ្យឈ្មោះ [redacted] មឿន ទេ កន្លងមកខ្លួនធ្លាប់បើកឡានជូនឈ្មោះ [redacted] មឿន ទៅទារលុយពីឈ្មោះ [redacted] រចនា ដែរ តែឈ្មោះ [redacted] រចនា ចេះតែពន្យាពេលសងម្តងថាថ្ងៃនេះថ្ងៃនោះហើយក្រោយមកឈ្មោះ [redacted] រចនា បានបិទទូរស័ព្ទ និងពេលខ្លះមិនទទួលទូរស័ព្ទទៀតផង ។ ខ្លួនបានដឹងថាឈ្មោះ [redacted] រចនា ជំពាក់លុយឈ្មោះ [redacted] មឿន ជាង១០.០០០០ដុល្លាអាមេរិក ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៦៤"គ" ចុះថ្ងៃទី២៦-០៧-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចដូចខាងក្រោម :

១-ផ្តន្ទាទោសលើ:

-ឈ្មោះ [redacted] រចនា ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់២ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន និងពិន័យជាប្រាក់ចំនួន៤.០០០.០០០រៀល (បួនលានរៀល) ដាក់ចូលក្នុងថវិការរដ្ឋពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦-៣-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា៣៩២នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឲ្យឈ្មោះ [redacted] រចនា សងសំណងចំនួន ១៣៨.០១៧ ដុល្លាអាមេរិក (ដប់បីម៉ឺនប្រាំបីពាន់ដប់ប្រាំពីរដុល្លាអាមេរិក)ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មឿន នៅពេលសាលក្រមនេះចូលជាស្ថាពរការទាមទារលើសពីនេះបដិសេធចោល។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃទី២៦-៧-២០១១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រចនា និងមេធាវីការពារឲ្យជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ



៣៩៥

[redacted]។

បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

*-បានឃើញពាក្យបណ្ដឹងឧទ្ធរណ៍លេខ៧៩៤ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ អឿង វិទ្ធា ជាមេធាវីការពារជនជាប់ចោទ បានប្ដឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខៈលេខ៦៤"គ" ចុះថ្ងៃទី២៦-០៧-២០១១ គ្រង់សេចក្ដីសម្រេចទាំងមូល ។*

-បានឃើញសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ៨៤ "ក្រ៥ង" ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ បានសម្រេចសេចក្ដីដូចខាងក្រោម៖

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] វិទ្ធា ជាមេធាវីទទួលសិទ្ធិពីឈ្មោះ [redacted] រចនា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៦៤ "គ" ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១២ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។ បើកសិទ្ធិប្ដឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញកំណត់ហេតុចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រចនា ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញសាលដីកាសម្រេចមុនអង្គសេចក្ដីលេខ៦៥ "ក្រ៥ង" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ បានសម្រេចសេចក្ដីដូចខាងក្រោម៖

-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] រចនា (ដូចមានសាវតាជាតិខាងលើ) ជាបណ្ដោះអាសន្ន ។

-បានឃើញដីកាបង្គាប់ឲ្យឃុំខ្លួនលេខ២៨០ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ របស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះទី៥ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារដូចខាងក្រោម៖

១-ឲ្យភ្នាក់ងារមានសមត្ថកិច្ច នៃកម្លាំងសាធារណៈ នាំខ្លួនជនជាប់ចោទដែលមានឈ្មោះ [redacted] រចនា ទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន(ម១) ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ។

២-ឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន(ម១) ទទួល និងឃុំខ្លួនជនជាប់ចោទរូបនេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

៣- ឲ្យភ្នាក់ងារ នៃកម្លាំងសាធារណៈទាំងអស់ សហការអនុវត្តឲ្យបានត្រឹមត្រូវតាមដីកានេះ ។

*-បានឃើញពាក្យបណ្ដឹងទាស់លេខ៤៨ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] រចនា បានប្ដឹងទាស់ នឹងសាលដីកាព្រហ្មទណ្ឌលេខៈលេខ៨៤ "ក្រ៥ង" ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ គ្រង់សេចក្ដីសម្រេចទាំងមូល ។*

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មឿន អវត្តមានៈ

-ជនជាប់ចោទឈ្មោះ [redacted] វចនា បានឆ្លើយថាៈ ខ្លួនប្តឹងទាស់នេះ ដោយសារខ្លួនមិនសុខចិត្តនឹងការសម្រេចនេះទេ ។ ខ្លួនពិតជាជំពាក់ប្រាក់ដើមបណ្តឹងចំនួន ១៣៨.០១៧ ដុល្លាអាមេរិក មែន តែខ្លួនបានសងគាត់ជាបន្តបន្ទាប់ នៅសល់តែចំនួន ៦០.០០០ដុល្លាអាមេរិក ប៉ុណ្ណោះ ។ ចំពោះការទូទាត់នេះ គឺមានខ្លះ អត់ខ្លះ ។ នៅក្នុងរឿងនេះ ដំបូងឡើយ ខ្លួនធ្លាប់ឲ្យគាត់បូមខ្សាច់ឲ្យខ្លួន ដោយធ្លាប់ខ្វះគាត់ចំនួនជាង ៦០ម៉ឺនដុល្លាអាមេរិក ឯណោះ តែខ្លួនទូទាត់ឲ្យគាត់អស់ហើយ ទើបតែក្រោយមកខ្លួនពុំមានចេតនាមិនសងប្រាក់ទេ តែដោយសារសេដ្ឋកិច្ចធ្លាក់ចុះ ទើបខ្លួនពុំទាន់មានប្រាក់សងទៅឲ្យដើមបណ្តឹង ។ ក្រោយមក នៅក្រោយពេលចាប់ខ្លួន ខ្លួនបានសងប្រាក់ឲ្យដើមបណ្តឹង ជាបន្តបន្ទាប់ មានចំនួន ១០.០០០ ដុល្លា (មួយម៉ឺនដុល្លាអាមេរិក) និងចំនួន ១០០០ ដុល្លា (មួយពាន់ដុល្លាអាមេរិក) នៅពេលនេះខ្លួនសំណូមពរ សុំលោកប្រធានសម្រេចលើកលែង ចោទប្រកាន់ដល់ខ្លួនផង ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានៈ នៅក្នុងរឿងនេះ ឃើញថាជនជាប់ចោទបានទទួលស្គាល់ថា ខ្លួនពិតជាបានជំពាក់ប្រាក់ដើមបណ្តឹងចំនួន ១៣៨.០១៧ ដុល្លាអាមេរិក មែន តែខ្លួនបានសងជាបន្តបន្ទាប់ នៅសល់តែចំនួន ៦០.០០០ដុល្លាអាមេរិក ប៉ុណ្ណោះ ។ ឃើញថា ជនជាប់ចោទមានចេតនាក្នុងការសងប្រាក់ទៅឲ្យដើមបណ្តឹងដែរ ប៉ុន្តែពុំមានលិខិតបញ្ជាក់ពីការសងនេះទេ និងយោងពាក្យសុំដកពាក្យបណ្តឹងរបស់ដើមបណ្តឹងចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ ផង ដូច្នេះសូមក្រុមប្រឹក្សា ពិនិត្យ ពិចារណា និងសម្រេច តាមច្បាប់ចុះ ។

-មេធាវីការពារឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានៈ នៅក្នុងរឿងនេះ ឃើញថាការចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] វចនា របស់តំណាងអយ្យការតាមមាត្រា៣៩១ និង៣៩២នៃក្រមព្រហ្មទណ្ឌថ្មី ពីបទរំលោភលើទំនុកចិត្ត គឺជាការចោទប្រកាន់មួយដែលផ្ទុយនឹងច្បាប់ ព្រោះនេះគឺកិច្ចសន្យា ហើយកូនក្តីខ្លួនបានទូទាត់បំណុលឲ្យទៅឈ្មោះ [redacted] មឿន តាមលំដាប់លំដោយរហូត ចំពោះនិយមន័យនៃការរំលោភលើទំនុកចិត្ត នោះ លុះត្រាតែកូនក្តីខ្លួនជួល រឺយកខ្សាច់គេហើយៗមិនទូទាត់លុយឲ្យគេ ហើយយកខ្សាច់ទៅជួល រឺបង្វិលដីនោះខុសពីឆន្ទៈរបស់ម្ចាស់ដី ទើបថា ជាបទរំលោភលើទំនុកចិត្ត ប៉ុន្តែកូនក្តីខ្លួនទទួលស្គាល់លើការជំពាក់នេះរហូត សូម្បីតែលោក [redacted] មឿន ក៏បានឆ្លើយទទួលស្គាល់នៅពេលសវនាការសាលាដំបូងថា កូនក្តីខ្លួនបានទូទាត់បណ្តើរៗហើយ ហើយកូនក្តីខ្លួននៅតែទទួលស្គាល់លើការជំពាក់នេះដដែល ។ ដូច្នេះ រឿងក្តីនេះ គឺជារឿងស៊ីវិលសុទ្ធសាធ ដូចនេះ ការចោទប្រកាន់របស់តំណាងអយ្យការវាមានវិមតិសង្ស័យមួយ ដែលបានជាប្រយោជន៍ដល់ជនជាប់ចោទ ម្យ៉ាងភាគីដើមបណ្តឹងបានពាក្យបណ្តឹងរបស់ខ្លួនហើយ ។ ដូច្នេះ សូមក្រុមប្រឹក្សាពិចារណាលើកលែងចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] វចនា ។

- ក្រោយពីបានស្តាបចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
- ក្រោយពីបានពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-ពាក្យបណ្តឹងទាស់លេខ ៤៨ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] រចនា ជាជនជាប់ចោទ បានប្តឹងទាស់ នឹងសាលដីកាព្រហ្មទណ្ឌលេខ៨៤ "ក្រVង" ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា ខ្លួនបានជំពាក់ប្រាក់ចំនួន ១៣៨.០១៧ ដុល្លាអាមេរិក ដែលខ្លួនមិនទាន់បានទូទាត់សងទៅដើមបណ្តឹងឈ្មោះ [redacted] មឿន ពិតប្រាកដ ដោយសារពេលនោះស្ថានភាពសេដ្ឋកិច្ចមានការធ្លាក់ចុះ ។ ប៉ុន្តែតាមអង្គហេតុបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទបានគេចវេសរហូត ពុំបានអនុវត្តកាតព្វកិច្ចសងបំណុលទៅឲ្យម្ចាស់បំណុលឡើយ ដែលបញ្ជាក់អំពីចេតនាគេបំបាត់ទ្រព្យសម្បត្តិ នាំឲ្យខូចផលប្រយោជន៍អ្នកដទៃ ដែលជនជាប់ចោទត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់ពីបទៈ រំលោភលើទំនុកចិត្ត យោងតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៣-ឈ្មោះ [redacted] រចនា បានឆ្លើយបញ្ជាក់ថា ក្រោយពេលចាប់ខ្លួន ខ្លួនបានសងប្រាក់ឲ្យដើមចោទជាបន្តបន្ទាប់ មានចំនួន ១០.០០០ ដុល្លា (មួយម៉ឺនដុល្លាអាមេរិក) និងចំនួន ១០០០ ដុល្លា (មួយពាន់ដុល្លាអាមេរិក) ប៉ុន្តែពុំមានឯកសារជាភស្តុតាងបញ្ជាក់លើការអះអាងនេះឡើយ ។ ដូច្នេះចំនួនប្រាក់ដែលជនជាប់ចោទត្រូវសងទៅដើមបណ្តឹងរដ្ឋប្បវេណី ពុំមានអ្វីត្រូវកែប្រែឡើយ ។

៤-អំពើប្រព្រឹត្តរបស់ជនជាប់ចោទជាបទល្មើសមជ្ឈឹម ម្យ៉ាងទៀតដើមបណ្តឹងរដ្ឋប្បវេណីបានសុំដកពាក្យបណ្តឹងតាមលិខិត ចុះថ្ងៃទី១៩ ខែកញ្ញា២០១៣ ដើម្បីទុកលទ្ធភាពឲ្យជនជាប់ចោទរកប្រាក់មកសងខ្លួនឲ្យបានគ្រប់ចំនួនវិញ ។ ហេតុដូច្នេះ គប្បីលើកយកមាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ មកពិចារណាដើម្បីជាប្រយោជន៍របស់ជនជាប់ចោទ ។

៥-សាលដីកាព្រហ្មទណ្ឌលេខ៨៤ "ក្រVង" ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍បានសម្រេចត្រឹមត្រូវហើយ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទ គប្បីកែប្រែឡើងវិញតាមការយល់ឃើញខាងលើ ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១-ទទួលបណ្តឹងទាស់លេខ៤៨ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ របស់ឈ្មោះ យ៉ែម រចនា ទុកជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៤"ក្រVង" ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែការផ្តន្ទាទោសក្នុងចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខ៦៤ "គ" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានដាក់ពន្ធនាគារកំណត់ ០២ ឆ្នាំ (ពីរឆ្នាំ) ត្រូវកែប្រែមកជា ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ ០២ខែ (ពីរខែ) ទោសនៅសល់ត្រូវព្យួរធម្មតា ។ ចំណុចផ្សេងទៀតនៃសាលក្រម ត្រូវរក្សាទុកជាបានការដដែល ។ យោងតាមមាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] រចនា តាមនីតិវិធី។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ,មេធាវីការពារសិទ្ធិជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

-បើកសិទ្ធិប្តឹងសាទុក្ខ តាមកំណត់ច្បាប់។

*សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការ អនុវត្តតាមសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរតាមច្បាប់ ។*

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធាន |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted], [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]